វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ANZ Royal

# សន្ទេបចក្ខុវិស័យប្រទេសកម្ពុជា*

ឆ្នាំ២០១២ លេខ ០៥

## អាទិភាពផ្នែកគោលនយោបាយសម្រាប់កំណើនប្រកបដោយចីរភាពនៅកម្ពុជា[១]

១. ធានាឲ្យមានកំណើនសម្រាប់គ្រប់គ្នា តាមរយៈការកែលំអសូចនាករសង្គម

ក. ផ្តល់ប្រព័ន្ធសុវត្ថិភាពសង្គមដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ ជាពិសេសគ្រួសាររស់នៅតាមតំបន់ជាយៗ និងគ្រួសារមានស្ត្រីជាមេគ្រួ

ខ. តម្រឹមបន្សុីគ្នា នូវគំនិតផ្តួចផ្តើមខាងសង្គមកិច្ចផ្សេងៗនាបច្ចុប្បន្ន ស្របតាមយុទ្ធសាស្ត្រជាតិការពារសង្គម និងដោយផ្តោតលើការបំបាត់ដើមហេតុនានា នៃវិសមភាពយេនឌ័រ។

២. រក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចទៅអនាគត

ក. រក្សាអតិផរណាឲ្យនៅត្រឹម ៥% ឬតិចជាង ដោយកាត់បន្ថយសម្ពាធ ដែលផុសចេញពីកំណើនលំហូរចូលមូលធន និងការឡើងថ្លៃផលិតផលនិងវត្ថុធាតុដើម

ខ. ជំរុញគោលនយោបាយសារពើពន្ធល្អសមស្រប ដើម្បីរក្សាសមត្ថភាពប្រកួតប្រជែងក្នុងវិស័យសំខាន់ៗ។

៣. ធ្វើពិពិធកម្មសេដ្ឋកិច្ចចេញពីវិស័យជាប្រពៃណី

ក. ឈានឡើងក្នុងខ្សែចង្វាក់បង្កើតតម្លៃបន្ថែម តាមការចាប់យកផលិតផលកសិកម្ម ឧស្សាហកម្ម និងសេវាកម្មថ្មីៗ និងការជ្រៀតចូលទៅក្នុងទីផ្សារថ្មីៗ

ខ. ធ្វើពិពិធកម្មសេដ្ឋកិច្ច ដើម្បីទាញយកអត្ថប្រយោជន៍ពីឱកាសល្អដែលតំបន់អាស៊ីកំពុងមានកំណើន និងមានភាពតភ្ជាប់គ្នាចុះឡើងកាន់តែប្រសើរ។

៤. លុបបំបាត់ឧបសគ្គរូបវន្ត ឧបសគ្គខាងស្ថាប័ន និងបទបញ្ញត្តិច្បាប់ ឈានទៅបង្កើតទីផ្សារតែមួយ នៃសហគមន៍សេដ្ឋកិច្ចអាស៊ាន នៅឆ្នាំ២០១៥

ក. តម្រឹមបន្សុីគោលនយោបាយផ្សេងៗ លើការដឹកជញ្ជូនឆ្លងកាត់ព្រំដែន និងធានាឲ្យមានបែបបទអនុវត្តប្រកបដោយប្រសិទ្ធភាព និងអាចទស្សទាយបាន

ខ. បន្តការប្រឹងប្រែង បង្កើនគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដោយផ្តោតលើការបង្ហើយគម្រោងស្តារជួសជុលផ្លូវដែក និងការតភ្ជាប់តំបន់ជាយៗប្រទេសកម្ពុជាទៅនឹងទីផ្សារតំបន់។

៥. ដោះស្រាយបញ្ហាភាពមិនសុីគ្នា រវាងជំនាញរបស់កម្លាំងពលកម្ម និងតម្រូវការរបស់វិស័យឯកជន

ក. កៀរគរ និងសម្របសម្រួលធនធានផ្សេងៗ ដើម្បីពង្រីកប្រព័ន្ធអប់រំ បណ្តុះបណ្តាល និងជំនាញវិជ្ជាជីវៈ (TVET) តាមការបង្កើតក្របខ័ណ្ឌថ្មីៗសម្រាប់ភាពជាដៃគូ រវាងវិស័យសាធារណៈ–ឯកជន

ខ. អនុវត្តវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ ដែលដោះស្រាយបញ្ហានៅគ្រប់កម្រិតនៃប្រព័ន្ធអប់រំរបស់កម្ពុជា។

៦. ដោះស្រាយភាពមិនសុីគ្នា រវាងគោលនយោបាយ និងសមត្ថភាពស្ថាប័ន

ក. កៀរគរ និងសម្របសម្រួលធនធានរបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីអភិវឌ្ឍស្ថាប័ននានាដែលអាចជួយពង្រឹងការអនុវត្តច្បាប់ និងក្របខ័ណ្ឌគោលនយោបាយដែលកាន់តែស្មុគស្មាញឡើងរបស់កម្ពុជា

ខ. បន្តកិច្ចប្រឹងប្រែងកាត់បន្ថយអំពើពុករលួយ ក្នុងស្ថាប័នសំខាន់ៗ ជាពិសេសក្នុងតុលាការ។

១ អាទិភាពផ្នែកនយោបាយទាំងនេះ ផ្អែកលើបទបង្ហាញ និងការពិភាក្សា នៅក្នុងសន្និសិទ្ទចក្ខុវិស័យប្រទេសកម្ពុជា នៅថ្ងៃទី១៦ កុម្ភៈ ២០១២។

* ផលិតផលនៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១២:
ភាពជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal

៧. លើកកម្ពស់គោលនយោបាយដែលជំរុញបានល្អនូវ ការចូលរួមរបស់វិស័យឯកជននៅក្នុងបណ្ដាញសេដ្ឋកិច្ចផ្សេងៗក្នុងតំបន់

   ក. កៀរគរស្ថាប័នស្រាវជ្រាវ ដើម្បីកំណត់ពីឧបសគ្គដែលរាំងការចូលរួមក្នុងតំបន់ ដោយប្រើការវិភាគតាមវិស័យ និងកសាងគោលនយោបាយ សម្រាប់ជួយវិស័យឯកជនឲ្យប្រើប្រាស់ឧត្តមភាពប្រៀបធៀប
   ខ. កសាង និងជំរុញវិធីសាស្ត្រល្អៗបំផុត ដែលអាចប្រើប្រាស់ក្នុងគម្រោងអនុវត្ត ក្រោមភាពជាដៃគូ រវាងវិស័យសាធារណៈ–ឯកជន និងដែលអាចយកទៅចម្លងធ្វើតាម និងពង្រីកថែមបាននៅក្នុងតំបន់។

៨. រៀបចំថ្លឹងថ្លែងសេដ្ឋកិច្ចឡើងវិញ ដើម្បីជួយដល់ប្រជាជនកម្ពុជាដែលភាគច្រើនធ្វើកសិកម្ម

   ក. លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការបង្កើនគុណភាពសេវាកម្ម ការដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍
   ខ. បន្តធ្វើកំណែទម្រង់លើឃុំសង្កាត់ ដើម្បីធានាឲ្យមានស្ថាប័នមូលដ្ឋានប្រកបដោយសមធម៌ និងភាពជាតំណាង ព្រមទាំងរបៀបរបបអភិវឌ្ឍល្អកាន់តែច្រើន។

៩. ប្រើឱកាសជាប្រធានអាស៊ាន ដើម្បីជំរុញចលនាតំបន់និយមមួយដែលរឹងប៉ឹង និងមានសមធម៌

   ក. កៀរគរការគាំទ្រ ដើម្បីភ្ជិតគម្លាតអភិវឌ្ឍន៍ រវាងបណ្ដាប្រទេសសមាជិកអាស៊ាន
   ខ. បង្ហាញឥទ្ធិពលអាស៊ាន ក្នុងពិភពលោក និងបង្កើនសកម្មភាពក្នុងឆាកនយោបាយអន្តរជាតិ។

១០. លើកទឹកចិត្តដល់ការអភិវឌ្ឍ ដែលមិនប៉ះពាល់ដល់ចីរភាពបរិស្ថាន

   ក. វិនិយោគលើការស្រាវជ្រាវពី ផលប៉ះពាល់លើបរិស្ថាននៃអន្តរាគមន៍ផ្នែកគោលនយោបាយ ដើម្បីឲ្យអ្នកបង្កើតគោលនយោបាយ អាចធ្វើការសម្រេចចិត្ត ដោយមានព័ត៌មានគ្រប់គ្រាន់
   ខ. លើកទឹកចិត្តវិស័យឯកជន ឲ្យអនុវត្តយុទ្ធសាស្ត្រវិនិយោគដែលមិនប៉ះពាល់ដល់ចីរភាពបរិស្ថាន៕

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (**វបសអ**/CDRI)
☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☏ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@cdri.org.kh, website: http://www.cdri.org.kh